គណបក្សប្រជាជនកម្ពុជា
គណៈកម្មាធិការកណ្ដាល

លេខៈ ២០៦ /សស.គក
/១៩

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ថ្ងៃ[illegible]ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៩

# សេចក្ដីកំណត់
## ស្ដីពីតួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការ របស់អង្គការចាត់តាំងយុវជនគណបក្សប្រជាជនកម្ពុជា

**យោង ៖** -សេចក្ដីសម្រេចលេខ ១០៥១៦ សស.គក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ ស្ដីពីការបង្កើតក្បាលម៉ាស៊ីនក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជា។

-សេចក្ដីកំណត់លេខ ១១៤ សណ.គក ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៩ ស្ដីពី តួនាទី ភារកិច្ច សិទ្ធិ អង្គការចាត់តាំង និងរបៀបរបបធ្វើការ របស់ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជា។

-សេចក្ដីសម្រេចលេខ ០០៦ សស.គក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៥ ស្ដីពីការបង្កើតក្រុមការងាររៀបចំអង្គការចាត់តាំងយុវជនគណបក្សប្រជាជនកម្ពុជានៅក្រៅប្រទេស។

-សំណូមពរចាំបាច់នៃការងារយុវជនរបស់គណបក្ស ក្នុងដំណាក់កាលថ្មី។

-ស្មារតីអង្គប្រជុំគណៈប្រចាំការ នៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល នាថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩

**គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល** កំណត់អំពីតួនាទី ភារកិច្ច សិទ្ធិ រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការ របស់អង្គការចាត់តាំងយុវជនគណបក្សប្រជាជនកម្ពុជា ដូចខាងក្រោម៖

### I.អំពីតួនាទី ភារកិច្ច និងសិទ្ធិ ៖

**ក. អំពីតួនាទី :**

អង្គការចាត់តាំងយុវជនគណបក្សប្រជាជនកម្ពុជា មានតួនាទីជាជំនួយការឱ្យគណបក្សលើការងារបំផុសចលនាយុវជនឱ្យគាំទ្របុព្វហេតុដ៏ត្រឹមត្រូវរបស់គណបក្ស។

**ខ. អំពីភារកិច្ច :**

១. ក្ដាប់ជាប់កម្មវិធីនយោបាយ គោលការណ៍ គោលនយោបាយ និងសេចក្ដីសម្រេចចិត្តនានា របស់គណបក្ស។

២. បញ្ជ្រាបកម្មវិធីនយោបាយ គោលការណ៍ គោលនយោបាយ សេចក្ដីសម្រេចចិត្តនានា របស់គណបក្សទៅក្នុងជួរយុវជន សំដៅលើកកម្ពស់ស្មារតីភ្ញាក់រឭក ជំនឿជាក់លើការដឹកនាំរបស់គណបក្ស ប៉ានការពារ

គណបក្ស ទៅបោះឆ្នោត និងបោះឆ្នោតជូនគណបក្ស។

៣. រៀបចំយុវជនដែលមានគ្រប់លក្ខណសម្បត្តិ ឱ្យចូលរៀនវគ្គបណ្តុះបណ្តាល ឬកម្មវិធីថ្នាក់ជាតិ និងអន្តរជាតិដែលរៀបចំដោយគណបក្ស អង្គការនានា ដែលធ្វើសហប្រតិបត្តិការជាមួយគណបក្ស និងបណ្តាប្រទេសជាមិត្ត។

៤. បំពាក់បំប៉នយុវជនជាវាគ្មិនតំណាងឱ្យគណបក្ស និងជ្រើសរើសវាគ្មិនឆ្នើម ដើម្បីចូលរួមក្នុងវេទិកាពិភាក្សាដេញដោលនានាទាំងមុនពេលបោះឆ្នោត ក្នុងយុទ្ធនាការឃោសនាបោះឆ្នោត និងក្រោយពេលបោះឆ្នោត។

៥. កសាងផែនការសកម្មភាពការងារយុវជនប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនគណៈកម្មាធិការគណបក្សអាណាព្យាបាលផ្ទាល់ ពិនិត្យ និងសម្រេច។

៦. អនុវត្តភារកិច្ចផ្សេងៗទៀត ដែលគណបក្សប្រគល់ឱ្យ។

**គ. <u>អំពីសិទ្ធិ</u> :**

១. ចាត់តាំងអនុវត្តរាល់ភារកិច្ចផ្សេងៗ ដែលគណបក្សថ្នាក់ខ្លួនប្រគល់ឱ្យ និងរួមសហការជាមួយគណៈកម្មាធិការគណបក្សគ្រប់ថ្នាក់ គ្រប់ផ្នែក ដើម្បីចាត់តាំងអនុវត្តផែនការសកម្មភាពការងារយុវជនដែលគណបក្សបានសម្រេច។

២. ប្រាស្រ័យទាក់ទងផ្ទាល់ជាមួយអង្គការដៃគូ ដើម្បីសម្របសម្រួលការងារដែលពាក់ព័ន្ធយុវជនគណបក្ស។

៣. ឧទ្ទេសនាមយុវជនល្អប្រពៃជូនអង្គការចាត់តាំងគណបក្ស ដែលមានសមត្ថកិច្ច ដើម្បីបញ្ចូលជាសមាជិកថ្មីរបស់គណបក្ស។

៤. អង្គការចាត់តាំងយុវជនគណបក្សថ្នាក់ណា មានសិទ្ធិឧទ្ទេសនាមយុវជនឆ្នើមជូនគណបក្សថ្នាក់នោះដើម្បីរៀបចំជួរអ្នកបន្តវេនរបស់គណបក្សថ្នាក់នោះ សម្រាប់ពេលអនាគត។

៥. យុវជនគណបក្សថ្នាក់កណ្តាលមានសិទ្ធិ៖

-បង្កើត និងរៀបចំសមាសភាពនៃលេខាធិការដ្ឋាន និងផ្នែកចំណុះរបស់ខ្លួន និងក្រុមការងាររៀបចំអង្គការចាត់តាំងយុវជនគណបក្សប្រជាជនកម្ពុជានៅក្រៅប្រទេស ស្របតាមសេចក្តីសម្រេច និងគោលការណ៍ណែនាំនានារបស់គណបក្ស។

- ណែនាំ កំណត់អំពីតួនាទី ភារកិច្ច និងរបៀបរបបធ្វើការរបស់លេខាធិការដ្ឋាន បណ្តាផ្នែកចំណុះ និងក្រុមការងាររៀបចំអង្គការចាត់តាំងយុវជនគណបក្សប្រជាជនកម្ពុជានៅក្រៅប្រទេស។

- សហការជាមួយគណៈកម្មាធិការគណបក្សគ្រប់ថ្នាក់ ដើម្បីជំរុញអនុវត្តឲ្យសម្រេចបាននូវរាល់ភារកិច្ចការងារយុវជនស្របតាមសេចក្តីសម្រេច និងគោលការណ៍ណែនាំនានារបស់គណបក្ស។

- ណែនាំ និងកំណត់ទិសដៅ ភារកិច្ច វិធីសាស្ត្រការងារយុវជន ដល់ក្រុមការងារយុវជនគណបក្សថ្នាក់ក្រសួង ស្ថាប័ន រាជធានី ខេត្ត និងក្រុមការងាររៀបចំអង្គការចាត់តាំងយុវជនគណបក្សប្រជាជនកម្ពុជា

នៅក្រៅប្រទេស ដើម្បីជំរុញអនុវត្តអោយបានសម្រេច នូវភារកិច្ចការងារយុវជនតាមសេចក្ដីសម្រេច និងគោលការណ៍ណែនាំរបស់គណបក្ស។

- រួមសហការ ជាមួយគណៈចលនា អង្គការ សមាគមនានា ដើម្បីសម្របសម្រួលការងារចលនាយុវជននៅក្នុងមជ្ឈដ្ឋាននីមួយៗ ពង្រឹង ពង្រីក កម្លាំងគាំទ្រ និងចូលរួមអនុវត្តកម្មវិធីនយោបាយរបស់គណបក្ស។

- លើកសំណើជូនគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាល ពិនិត្យ សម្រេច អំពីការសម្រួលភារកិច្ច និងតែងតាំងសមាសភាពយុវជនគណបក្សថ្នាក់កណ្ដាល ក្រុមការងាររៀបចំអង្គការចាត់តាំងយុវជនគណបក្សប្រជាជនកម្ពុជានៅក្រៅប្រទេស និងក្រុមការងាររៀបចំអង្គការចាត់តាំងយុវជនគណបក្សនៅតាមបណ្ដាប្រទេស ឬតំបន់។

៦. ក្រុមការងារយុវជនគណបក្សថ្នាក់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លើកសំណើជូនគណៈកម្មាធិការគណបក្សអាណាព្យាបាលផ្ទាល់ ពិនិត្យ សម្រេច អំពីការសម្រួលភារកិច្ច និងតែងតាំងសមាសភាពក្រុមការងារយុវជនគណបក្សថ្នាក់ខ្លួន។

៧. ក្រុមការងារយុវជនគណបក្សថ្នាក់មូលដ្ឋាន លើកសំណើជូនគណៈកម្មាធិការគណបក្សមូលដ្ឋាន ពិនិត្យ សម្រេច អំពីការរៀបចំសមាសភាពក្រុមការងារយុវជនគណបក្សថ្នាក់ខ្លួន និងក្រុមសកម្មជនយុវជនគណបក្សនៅតាមសាខាបក្ស។

៨. ក្រុមការងាររៀបចំអង្គការចាត់តាំងយុវជនគណបក្សប្រជាជនកម្ពុជានៅក្រៅប្រទេស សម្របសម្រួល និងលើកសំណើជូនគណៈកម្មាធិការគណបក្សនៅក្រៅប្រទេស ពិនិត្យ សម្រេច អំពីការរៀបចំសមាសភាពក្រុមការងារយុវជនគណបក្សនៅក្រៅប្រទេស និងក្រុមសកម្មជនយុវជននៅតាមសាខាបក្ស។

## II.**អំពីរចនាសម្ព័ន្ធ**

១. អង្គការចាត់តាំងយុវជនគណបក្សប្រជាជនកម្ពុជាត្រូវបានចាត់តាំងឡើងនៅក្នុង និងនៅក្រៅប្រទេសដូចខាងក្រោម៖

-យុវជនគណបក្សថ្នាក់កណ្ដាល ស្ថិតក្រោមការដឹកនាំរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាល។

-ក្រុមការងារយុវជនគណបក្សថ្នាក់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ស្ថិតក្រោមការដឹកនាំរបស់គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត និងចំណុះគណៈកម្មការគ្រប់គ្រងសមាជិក ។

-ក្រុមការងារយុវជនគណបក្សថ្នាក់ក្រុង ស្រុក ខណ្ឌ ស្ថិតក្រោមការដឹកនាំរបស់គណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ។

-ក្រុមការងារយុវជនគណបក្សថ្នាក់មូលដ្ឋាន ស្ថិតក្រោមការដឹកនាំរបស់គណៈកម្មាធិការគណបក្សមូលដ្ឋាន។

-ក្រុមការងារយុវជនគណបក្សនៅក្រៅប្រទេស ស្ថិតក្រោមការដឹកនាំរបស់គណៈកម្មាធិការគណបក្ស ឬ សាខាបក្សប្រចាំប្រទេសនានា។

-ក្រុមសកម្មជនយុវជនគណបក្ស ស្ថិតក្រោមការដឹកនាំរបស់សាខាបក្ស។

២. រចនាសម្ព័ន្ធនៃយុវជនគណបក្សថ្នាក់កណ្តាល និងក្រុមការងារយុវជនគណបក្សគ្រប់ថ្នាក់ត្រូវមាន៖

-ប្រធាន ០១ រូប អនុប្រធានមួយចំនួន និងសមាជិកតាមចំនួនសមស្រប ហើយដែលក្នុងនោះអាចរៀបចំឱ្យមានសមាជិកអចិន្ត្រៃយ៍មួយចំនួន តាមសំណូមពរនៃការងារ ស្របតាមគោលការណ៍ចាត់តាំងរបស់គណបក្ស។

-ត្រូវបែងចែកភារកិច្ចឱ្យគ្រប់សមាសភាពនៃថ្នាក់នីមួយៗ ទទួលបន្ទុកលើការងារជាក់ស្តែងតាមការចាំបាច់។

៣. សមាសភាពនៃយុវជនគណបក្សថ្នាក់កណ្តាល និងក្រុមការងារយុវជនគណបក្សតាមបណ្តាថ្នាក់ត្រូវជ្រើសចេញពីជួរថ្នាក់ដឹកនាំ និងពីសមាជិកគណបក្សក្នុងស្រទាប់យុវជនដែលជាមន្ត្រី លោកគ្រូ អ្នកគ្រូ និស្សិត សិស្ស សកម្មជនយុវជន ឃោសនិក ពាណិជ្ជករ...។ល។ ដែលមានឆន្ទៈ សមត្ថភាព និងពេលវេលាអាចបំពេញភារកិច្ចដែលបានកំណត់។ ត្រូវយកចិត្តទុកដាក់ចាត់តាំងឱ្យមានសមាសភាពនារី ក្នុងរចនាសម្ព័ន្ធអង្គការចាត់តាំងយុវជនគ្រប់ថ្នាក់។

៤. ប្រធានក្រុមការងារយុវជនគណបក្សថ្នាក់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវបានចាត់តាំងជាសមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល។

៥. គណៈអចិន្ត្រៃយ៍ នៃយុវជនគណបក្សថ្នាក់កណ្តាល ដែលរួមមាន៖ ប្រធាន អនុប្រធាន និងសមាជិកអចិន្ត្រៃយ៍ ទទួលខុសត្រូវដឹកនាំការងារជាប្រចាំ ដោយមានរចនាសម្ព័ន្ធដែលជាផ្នែកចំណុះដូចខាងក្រោម៖

- លេខាធិការដ្ឋាន
- ផ្នែកចាត់តាំង និងកសាងកម្លាំង
- ផ្នែកឃោសនាអប់រំ
- ផ្នែកព័ត៌មានបណ្តាញផ្សព្វផ្សាយសង្គម
- ផ្នែកទំនាក់ទំនងអន្តរជាតិ
- ផ្នែកបណ្តុះបណ្តាល
- ផ្នែកហិរញ្ញវត្ថុ
- និងផ្នែកផ្សេងៗតាមការចាំបាច់។

៦. ក្រុមការងារយុវជនគណបក្សថ្នាក់ក្រសួង ស្ថាប័ន រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំរចនាសម្ព័ន្ធផ្នែកចំណុះរបស់ខ្លួន ស្របតាមសំណូមពរភារកិច្ចជាក់ស្តែង។

៧. ក្រុមការងាររៀបចំអង្គការចាត់តាំងយុវជនគណបក្សប្រជាជនកម្ពុជានៅក្រៅប្រទេស ជាយន្តការជំនួយឱ្យយុវជនគណបក្សថ្នាក់កណ្តាល លើការងាររៀបចំ និងពង្រឹងអង្គការចាត់តាំងយុវជនគណបក្សនៅក្រៅប្រទេស។

III. **អំពីរបៀបរបបធ្វើការ ៖**

១. អង្គការចាត់តាំងយុវជនគណបក្សគ្រប់ថ្នាក់ ធ្វើការតាមរបបសមូហភាពដឹកនាំម្នាក់ៗទទួលខុសត្រូវ។

២. អង្គការចាត់តាំងយុវជនគណបក្សគ្រប់ថ្នាក់ ត្រូវប្រជុំជាសាមញ្ញមួយខែម្តង ក្នុងករណីចាំបាច់អាចប្រជុំជាវិសាមញ្ញបាន។

៣. ខ្លឹមសារ និងលទ្ធផលនៃកិច្ចប្រជុំត្រូវរាយការណ៍សុំយោបល់ណែនាំពីគណបក្សអាណាព្យាបាលផ្ទាល់។

៤. ក្រុមការងារយុវជនគណបក្សថ្នាក់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ជូនគណៈកម្មាធិការគណបក្សសាមីប្រចាំខែ និងចម្លងជូនយុវជនគណបក្សថ្នាក់កណ្តាល។

IV.**អំពីហិរញ្ញវត្ថុយុវជនគណបក្សប្រជាជនកម្ពុជា ៖**

ប្រភពហិរញ្ញវត្ថុរបស់យុវជនគណបក្សបានមកពី៖

១. ការជួយឧបត្ថម្ភរបស់គណបក្ស

២. ការចូលរួមពីសមាជិក សមាជិកាគណបក្ស

៣. ចំណូលពីអាជីវកម្មស្របច្បាប់ និង

៤. ការជួយឧបត្ថម្ភរបស់សប្បុរសជននានា។

សេចក្តីកំណត់នេះជំនួសឱ្យសេចក្តីកំណត់ **លេខ ១១៤ សណ.គក ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៩** ស្តីពីតួនាទី ភារកិច្ច សិទ្ធិ អង្គការចាត់តាំង និងរបៀបរបបធ្វើការ របស់ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជា និងត្រូវបានកែសម្រួលឈ្មោះ «ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល» ដែលមានចែងក្នុង**សេចក្តីសម្រេចលេខ ១០៥១៦ សស.គក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩** ស្តីពីការបង្កើតក្បាលម៉ាស៊ីនក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជា មកជា «យុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល» ស្របតាមសេចក្តីកំណត់ថ្មីនេះ។

ខុទ្ទកាល័យ គណៈចាត់តាំង គណៈចលនាមហាជន នៃគណៈកម្មាធិការកណ្តាល គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត គណៈកម្មាធិការគណបក្សនៅក្រៅប្រទេស និងស្ថាប័នគណបក្សដែលពាក់ព័ន្ធ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ ឲ្យទទួលបានប្រសិទ្ធភាពខ្ពស់។

**ជ.គណៈអចិន្ត្រៃយ៍**

**ប្រធាន**

**ហ៊ុន សែន**